# សេចក្តីប្រកាសព័ត៌មាន

*រាជធានីភ្នំពេញទី ២៥ ខែមករា ឆ្នាំ ២០១៨*

## រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
## ប្រារព្ធពិធីសន្និបាតបូកសរុបវឌ្ឍនភាពការងារ វិស័យអាកាសចរស៊ីវិលកម្ពុជា
## ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍ការងារពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣

**រាជធានីភ្នំពេញ៖** នាព្រឹកថ្ងៃព្រហស្បតិ ២កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ក្រោមអធិបតីភាព **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញបើកសន្និបាតបូកសរុបវឌ្ឍនភាពការងារវិស័យអាកាសចរស៊ីវិលកម្ពុជា ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍ការងារពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ ព្រមទាំងបានសម្តែងការសាទរចំពោះសមិទ្ធផលការងារសំខាន់ៗ ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលសម្រេចបានចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧។

ច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងវិធានមួយចំនួនក្នុងវិស័យអាកាសចរស៊ីវិលកម្ពុជា ត្រូវបានធ្វើបច្ចុប្បន្នភាព និងប្រកាសឱ្យប្រើប្រាស់ (Cambodia Civil Aviation Regulation-CCAR) ដែលទាក់ទងដល់បច្ចេកទេសលទ្ធភាពហោះហើរ (AIR) ប្រតិបត្តិការហោះហើរ (OPS) ការផ្តល់វិញ្ញាបនបត្រ (PEL) អធិការកិច្ច(Inspection) ការចេញវិញ្ញាបនបត្រ (Certification) លើសេវាកម្មអាកាសយានដ្ឋាន សេវាកម្មត្រួតពិនិត្យចរាចរណ៍ដែនអាកាស ក្រុមហ៊ុនអាកាសចរណ៍ និងសន្តិសុខអាកាសចរណ៍ រួមទាំងបទប្បញ្ញត្តិបច្ចេកទេសផ្សេងៗទៀត និងបានធ្វើកិច្ចការកែសម្រួលបន្ថែម ជាបន្តបន្ទាប់ទៅលើបទប្បញ្ញត្តិ នីតិវិធី សេចក្តីណែនាំ ព្រមទាំងបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីឱ្យស្របតាមតម្រូវការ និងអនុសាសន៍ របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។ ក្នុងនោះដែរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក៏បានដាក់ឱ្យប្រើប្រាស់កម្មវិធីសន្តិសុខអាកាសចរជាតិ (National Security Program) កម្មវិធីសុវត្ថិភាពជាតិ (SSP-State Safety Program) កម្មវិធីសុវត្ថិភាពនាំផ្លូវអាកាស កម្មវិធីត្រួតពិនិត្យសុវត្ថិភាព (Safety Oversight and Audit) ព្រមទាំងខិតខំអនុវត្តផែនការសកម្មភាពកែតម្រូវរបស់ខ្លួនជាបណ្តើរៗ ស្របតាមរបកគំហើញនៃកម្មវិធីត្រួតពិនិត្យសុវត្ថិភាពសកល របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO-USOAP)។ នៅក្នុងកម្រិតថ្នាក់ជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានផ្សព្វផ្សាយ និងស្វែងយល់ ស្តីពីការអនុវត្តច្បាប់អាកាសចរស៊ីវិលដល់ស្ថាប័នរដ្ឋ និងសហគ្រាសដឹកជញ្ជូនឯកជន។ ទន្ទឹមនឹងនេះ ដើម្បីឱ្យវិស័យអាកាសចរស៊ីវិលកម្ពុជា ទទួលបានការគ្រប់គ្រងលើផ្នែកសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

បាននឹងកំពុងរៀបចំស្វែងរកជំនួយបច្ចេកទេសក្នុងការរៀបចំបទប្បញ្ញត្តិផ្នែកសេដ្ឋកិច្ចអាកាសចរស៊ីវិល និងបទប្បញ្ញត្តិបច្ចេកទេសមួយចំនួនបន្ថែមទៀត ដើម្បីធានាឱ្យបាននូវបរិការកាសធុរកិច្ច ក្នុង វិស័យដឹកជញ្ជូនផ្លូវអាកាសប្រកបដោយសមធម៌ និងតម្លាភាពជានិរន្តរ៍ភាព។

ស្ថិតក្នុងបរិបទនៃការរីកចម្រើនគួរឲ្យកត់សំគាល់នេះ ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជាបានវិនិយោគ ១០០លានដុល្លាអាមេរិក ដើម្បីបង្កើនសមត្ថភាពទ្វេដង ទំហំស្ថានីយ៍អ្នកដំណើរ សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដែលអាចទទួលអ្នកដំណើរបានដល់ ១០លាននាក់ ជាឆ្លើយតបទៅនឹងតម្រូវការកំណើនអ្នកដំណើរអន្តរជាតិតាមផ្លូវអាកាសយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា។ អាកាសយានដ្ឋានអន្តរជាតិទាំង៣ ត្រូវបានធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានទាំងសោភ័ណ្ឌភាព និងសមត្ថភាពក្នុងការផ្តល់សេវាកម្មអាកាសយានដ្ឋានជូនអតិថិជន ដោយបានពង្រីកស្ថានីយ៍អ្នកដំណើរ ចំណតអាកាសយាន (អាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានចំនួន៦ចំណត និងចំណតអាកាសយានដ្ឋានអន្តរជាតិសៀមរាបមានចំនួន៥ចំណត) និងបានពង្រីកទំហំផ្លូវរត់ និងពង្រឹងតំបន់សុវត្ថិភាពចុងផ្លូវរត់០៥ (អាកាសយានដ្ឋានអន្តរជាតិសៀមរាប)។ បានបំពាក់ឧបករណ៍លើដីថ្មី បំពាក់ឧបករណ៍ស្ថានីយ៍អ្នកដំណើរថ្មីៗ និងទំនិញព្រមទាំងបានបណ្តុះបណ្តាលបុគ្គលិកសម្រាប់ស្ថានីយ៍អ្នកដំណើរក្នុងស្រុក និងស្ថានីយ៍អ្នកដំណើរអន្តរជាតិនៅអាកាសយានដ្ឋានអន្តរជាតិទាំង៣។ ការអភិវឌ្ឍអាកាសយានដ្ឋានអន្តជាតិថ្មី នៅខេត្តសៀមរាប និងខេត្តកោះកុង (តារាសាគរ) និងខេត្តកណ្តាល (ក្រុងតាខ្មៅ) តាមរយៈការចូលរួមភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)។ ជាមួយនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានខិតខំប្រឹងប្រែងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានក្នុងស្រុកផងដែរ ដោយប្រើប្រាស់ថវិកាជាតិ ដែលទទួលបានការវិភាជផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅបម្រើសេវាកម្មអាកាសចរណ៍ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិនានា។

តាមរយៈគម្រោងការពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីមានសមត្ថភាពឈានទៅការអនុវត្តប្រព័ន្ធនាំផ្លូវអាកាសថ្មីតាមផ្កាយរណប (New CNS/ATM Systems) ដែលជាគម្រោងជំនួយបច្ចេកទេសរបស់រាជរដ្ឋាភិបាលជប៉ុនត្រូវបានបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៥ ប្រទេសកម្ពុជាបានដាក់ឱ្យអនុវត្តនូវបទដ្ឋានហោះហើរថ្មី ដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណប (PBN) នៅអាកាសយានដ្ឋានអន្តរជាតិទាំង៣ រួមមាន៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០១៣ អាកាសយានដ្ឋានអន្តរជាតិសៀមរាប នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៦។ ការអនុវត្តប្រព័ន្ធនាំផ្លូវអាកាសថ្មី បាននិងកំពុងចូលរួមកាត់បន្ថយបាននូវពេលវេលា រយៈចំងាយ និងបង្កើនប្រសិទ្ធភាពដល់ប្រតិបត្តិការហោះហើរ ដែលធ្វើឱ្យមានថ្លៃដើមទាប និងបង្កើនបាននូវសមត្ថភាព និងគុណភាពក្នុងការប្រកួតប្រជែងខ្ពស់ជាងមុន។ លើសពីនេះទៀត ក៏បានចាប់ផ្តើមធ្វើទំនើបកម្មប្រព័ន្ធ ការផ្តល់ព័ត៌មានអាកាសចរណ៍ ពីការប្រើប្រព័ន្ធ AIS ទៅប្រើប្រព័ន្ធ AIM វិញ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការគ្រប់គ្រងចរាចរណ៍ដែនអាកាសកម្ពុជា។

ទន្ទឹមនឹងនេះដែរ ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស៖ តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងសាធារណរដ្ឋកូរ៉េ និងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានទទួល

ជំនួយឥតសំណងសម្រាប់គម្រោងការសាងសង់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលនៅកម្ពុជា មានទឹកប្រាក់ចំនួន១០.១០លានដុល្លាអាមេរិក ដែលមានរយៈពេលអនុវត្ត០៤ឆ្នាំ ចាប់អនុវត្តពីឆ្នាំ២០១៤-២០១៧ ដោយបានផ្តល់នូវអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ជាមួយនឹងការបំពាក់ឧបករណ៍សម្ភារៈបរិក្ខារបច្ចេកទេសទំនើប បម្រើឲ្យការបណ្តុះបណ្តាល ការរៀបចំផែនការមេ សម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីឱ្យក្លាយជាគ្រូបង្គោលនាពេលអនាគត ក្នុងគោលបំណង ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអាកាសចរស៊ីវិលឱ្យមានសមត្ថភាពប្រកួតប្រជែងខ្ពស់ និងលើកកំពស់គុណភាព និងប្រសិទ្ធភាពការងារ ធានាបាននូវសន្តិសុខ និងសុវត្ថិភាពខ្ពស់ សម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ស្របតាមស្តង់ដារ និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

បច្ចុប្បន្ននេះ ចំពោះសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ព្រះរាជាណាចក្រកម្ពុជាមានក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកចំនួន១០ កំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញចេញ-ចូល លើដំណាក់ផ្លូវហោះហើរក្នុងស្រុក និងអន្តរជាតិ មានដូចជាៈ ១.ក្រុមហ៊ុនខាមបូឌាអង្គរអ៊ែរ ២.ក្រុមហ៊ុន ស្កាយអង្គរ អ៊ែរឡាញ ៣.ក្រុមហ៊ុន ខេមបូឌា បាយ៉ន អ៊ែរឡាញ ៤.ក្រុមហ៊ុន បាសសាកា អ៊ែរ ៥.ក្រុមហ៊ុន ជេស៊ុ ខាមបូឌារ អ៊ិនធើណេសសិណល អ៊ែរឡាញ ៦.ក្រុមហ៊ុន ឡានម៉ី អ៊ែរឡាញ ៧.ក្រុមហ៊ុន ស្មលផ្លែនណេត និងមានក្រុមហ៊ុនឧទ្ធម្ភាគចក្រចំនួនពីរគឺ ៨.ក្រុមហ៊ុន ហេលិខបធ័រ ខេម បូឌា ៩.ក្រុមហ៊ុន ហេលិស្តារ ខេមបូឌា ១០. ក្រុមហ៊ុន Union Development Group។ ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកមួយចំនួនទៀត ដែលបាននឹងកំពុងស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការហោះហើរ (AOC) ពី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីអាចដំណើរការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញក្នុងស្រុក និងក្រៅស្រុកនៅព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀតនៅមានក្រុមហ៊ុនអាកាសចរណ៍បរទេសចំនួន៤០ផ្សេងទៀត ក្រុមហ៊ុនកំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាលក្ខណៈអន្តរជាតិមកកាន់ព្រះរាជាណាចក្រកម្ពុជា (មិនរាប់បញ្ចូលនូវក្រុមហ៊ុនអាកាសចរណ៍ដែលហោះហើរជាលក្ខណៈជួល (Charter))។

ចំនួនជើងហោះហើរ (Flight Movement) ជាមធ្យមនៅអាកាសយានដ្ឋានអន្តរជាតិទាំងបីមានដូចជាៈ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មានចំនួនជាមធ្យម ៥៥ជើង ក្នុងមួយថ្ងៃ ឬ ១៦៥០ជើងក្នុងមួយខែ។ នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប មានចំនួនជាមធ្យម ៥៧ជើង ក្នុងមួយថ្ងៃ ឬ១៧១០ជើង ក្នុងមួយខែ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ មានចំនួនជាមធ្យម ៨ជើង ក្នុងមួយថ្ងៃ ឬ២៤០ជើង ក្នុងមួយខែ។ ដោយឡែកការហោះហើរឆ្លងកាត់ដែនអាកាសកម្ពុជា (Overflight) មានចំនួនជាមធ្យម ១៥៣ជើង ក្នុងមួយថ្ងៃ ឬ ៤៥៨៥ជើងក្នុងមួយខែ។

ចំនួនអ្នកដំណើរមានកំណើនដល់ចំនួន៨លាននាក់(ចេញ-ចូល) នៅអាកាសយានដ្ឋានអន្តរជាតិទាំងបី និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសមានកំណើនឈានដល់ចំនួន ៦០ពាន់តោន (នៅអាកាសយានដ្ឋានអន្តរជាតិទាំងបី) ។

ជាមួយកំណើនខាងលើនេះ វិស័យអាកាសចរស៊ីវិលកម្ពុជាបានបង្កើតការងារដោយផ្ទាល់ និងដោយប្រយោលមានចំនួន ១,៧លានការងារ ស្មើនឹង ២០% នៃចំនួនចំនួនប្រជាជនធ្វើការសរុបរបស់ប្រទេសកម្ពុជា និងបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចដោយផ្ទាល់ និងដោយប្រយោល ប្រមាណជា២,៧ពាន់លានដុល្លាស្មើនឹង

១៧% នៃ ផសស (GDP)។ ព្រមទាំងបានគាំទ្រ និងជម្រុញ (ធ្វើឲ្យមានកំណើន) ដល់វិស័យទេសចរណ៍ និងពាណិជ្ជកម្ម ការទាក់ទាញ និងការជម្រុញដល់ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងធុរកិច្ចក្នុងស្រុក។ ក្រៅពីនេះ វិស័យអាកាសចរណ៍បានធ្វើឱ្យមានការតភ្ជាប់រវាងប្រជាជន និងប្រជាជន ប្រទេសនិងប្រទេស វប្បធម៌ និងវប្បធម៌ ផ្តល់នូវមាត់ច្រកទៅកាន់ទីផ្សារ ការផ្សារភ្ជាប់ ឬធ្វើឱ្យកាន់តែជិតឡើងរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍រួច។

ជាមួយនឹងការអបអរសាទរនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន** ក៏បានផ្តល់អនុសាសន៍មួយចំនួនដល់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដោយផ្តោតសំខាន់លើការបន្តអនុវត្តន៍គោលនយោបាយ និងកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ដើម្បីលើកកម្ពស់បរិយាសធុរកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្មជូនវិស័យឯកជន ជាពិសេសការធ្វើពិពិធកម្មទីផ្សារថ្មីៗបន្ថែម សម្រាប់ឈានទៅធ្វើសមាហរណកម្មសេវាកម្មដឹកជញ្ជូនក្នុងស្រុកចូលទៅក្នុង បណ្តាញសេវាកម្មដឹកជញ្ជូនក្នុងតំបន់ និងពិភពលោក។

នៅក្នុងឱកាសនោះផងដែរ **ឯកឧត្តម ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយបើកចំហដេីងមេឃ ដែលជាលទ្ធផលបានធ្វើឲ្យវិស័យអាកាសចរស៊ីវិលកម្ពុជាមានការរីកចម្រើនទៅមុខយ៉ាងខ្លាំងស្ថិតក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ និងកំពុងប្រែក្លាយព្រះរាជាណាចក្រកម្ពុជាជាមជ្ឈមណ្ឌលអាកាសចរណ៍ និងទេសចរណ៍មួយ ដែលមានភាពទាក់ទាញ ក្នុងតំបន់ និងពិភពលោក។ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងបានសំណូមពរដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រកាន់ខ្ជាប់នូវវប្បធម៌ការងារល្អនេះបន្តទៀត ដើម្បីនាំមកនូវភាពរីកចម្រើន ក៏ដូចជាសមិទ្ធផលថ្មីៗបន្ថែមទៀត សម្រាប់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក៏ដូចជាវិស័យអាកាសចរស៊ីវិលកម្ពុជាទាំងមូល ជាពិសេសចូលរួមលើកស្ទួយដល់ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា៕